Fo 17

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

&&& ❊ &&&



# គោលការណ៍ណែនាំសំរាប់ប្រព័ន្ធនៃការធ្វើផែនការ គ្រប់គ្រងព្រៃសម្បទាន

Principle to make the plan for Forestry Management

# ទគ្គទី ១

# គោលការណ៍ណែនាំសំរាប់ប្រព័ន្ធនៃការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន

## ១- សេចក្តីផ្តើម

ព្រៃឈើប្រទេសកម្ពុជាមានលក្ខណៈពិសេសសំរាប់ជីវិតមនុស្ស និង មានសារៈសំខាន់ជាមូលដ្ឋានសំរាប់បរិស្ថាន សង្គម និង សេដ្ឋកិច្ចក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ ព្រៃឈើមានតំលៃសំរាប់ផលិតកម្មឈើហ៊ុប ឈើថាមពល និង ជាប្រភពផ្តល់អាហារសំរាប់ការរស់នៅរបស់ប្រជាជនក្នុងសហគមន៍ជនបទ ។ ព្រៃឈើមានអត្ថប្រយោជន៍សំរាប់និយតភាពចរន្តទឹកទន្លេមេគង្គ និង ទន្លេផ្សេងទៀត ព្រមទាំងការពារមិនអោយមានការហូរច្រោះដី និង ការអភិរក្សជីវៈចំរុះ ។

គោលការណ៍ណែនាំនេះដាក់ចុះនូវក្របខ័ណ្ឌការងារជាទូទៅ ដើម្បីគ្រប់គ្រងព្រៃសម្បទានក្នុងប្រទេសកម្ពុជា និង ធ្វើការគ្រប់គ្រងលើទិដ្ឋភាពដទៃទៀតក្នុងវិស័យព្រៃឈើ និង វិស័យផ្សេងទៀត។ ការបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងព្រៃ សម្បទាន នឹងនាំទៅដល់ការគ្រប់គ្រងព្រៃឈើដែលមានតុល្យភាព និរន្តរភាព និង មានប្រសិទ្ធិភាព ហើយនឹងទាក់ទាញផងដែរនូវការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងព្រៃឈើ ដើម្បីសំរេចបាននូវសេចក្តីត្រូវការផ្នែកសង្គម-សេដ្ឋកិច្ច វប្បធម៌ និង ជំនឿសាសនា សំរាប់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្ន និងពេលអនាគត។

ការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន និង វដ្តនៃការអនុវត្តន៍ផែនការ ត្រូវបានស្នើឡើងដោយរួមបញ្ចូលនូវរបនាសម្ព័ន្ធដែលទាក់ទងទៅនឹងធាតុសំខាន់ៗនៃការធ្វើផែនការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែង និង ប្រព័ន្ធប្រមូលផលព្រៃឈើ ។ ការធ្វើផែនការគ្រប់គ្រង និង វដ្តនៃការអនុវត្តន៍អាចដាក់ចុះនូវទស្សនៈវិស័យរយៈពេលវែង និង ការអនុវត្តន៍សមស្របសំរាប់ការអភិរក្ស និង ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ដើម្បីធ្វើផែនការគ្រប់គ្រង និង វដ្តនៃការអនុវត្តន៍ផែនការចាំបាច់ត្រូវយល់ដឹងឱ្យបានច្បាស់ពីទំនាក់ទំនង និង អន្តរកម្មនានា។

គំនូសបំព្រួញនៅទំព័របន្តបន្ទាប់នេះនឹងបង្ហាញជូននូវទំនាក់ទំនង និង បញ្ហាគន្លឹះដែលជាមូលដ្ឋាននៃការធ្វើផែនការ និង វដ្តនៃការអនុវត្តន៍ផែនការ។

## គំនូសបំព្រួញទី ១


តើប្រព័ន្ធនៃការធ្វើផែនការគ្រប់គ្រងព្រៃឈើកំរិតណាដែលសមស្របនឹងស្ថានភាពប្រទេសកម្ពុជា?
At what level does a forest management planing system fit in Cambodia?
កំរិតជាតិ
National level
កំរិតខេត្ត
Provincial level
កំរិតព្រៃសម្បទាន
Forest Concession level
កំរិតអនុតំបន់
Forest Compartment level
កំរិតគុប និង ប្លុក
Forest Coupe and Block level
ចម្លើយ! Answer!
គ្រប់កំរិតទាំងអស់ All of these levels
តើកំរិតណាមួយដែលសំខាន់បំផុត?
Which level is most important?
ចម្លើយ! Answer!
គ្រប់កំរិតទាំងអស់ : All of these levels.
ការធ្វើផែនការគ្រប់គ្រងព្រៃសម្បទានមិនអាចដំណើរការបាន
ដោយការបាត់បង់កំរិតណាមួយនៃប្រព័ន្ធនេះឡើយ
Forest management planning can not
work with any link missing from the chain

<u>គំនូសបំព្រួញទី ២</u>



គំនូសបំព្រួញទី ៧


ការទទួលបានទីផ្សាររយៈពេលវែងនៃឧស្សាហកម្មព្រៃឈើ
និង ការអនុវត្តន៍របស់ឧស្សាហកម្មព្រៃឈើនោះ
Long term market acceptance of the industry and their practices
ការទទួលបានមកវិញជាហិរញ្ញវត្ថុ
គ្រប់គ្រាន់សំរាប់ក្រុមហ៊ុនព្រៃឈើ
Adequate financial returns to forest companies
ការទទួលបានមកវិញជាហិរញ្ញវត្ថុ
គ្រប់គ្រាន់ សំរាប់ម្ចាស់ធនធានព្រៃឈើ
Adequate financial returns for resource owners
តើអ្វីជាតំរូវការដើម្បីទទួលបានឧស្សាហកម្មព្រៃឈើមានលក្ខណៈចីរភាព ?
What is needed to have a viable commercial forest industry?
ការធានាសិទ្ធិកាន់កាប់ធនធានព្រៃឈើ
Secure tenure over the forest resource
ការធានាផ្គត់ផ្គង់ឈើដើម្បីឱ្យការវិនិយោគ
ផ្នែកឧស្សាហកម្មអាចដំណើរការបាន
Guaranteed wood supply to enable commercial investment
ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដើម្បី
ធានាការផ្គត់ផ្គង់ធនធានព្រៃឈើបានយូរអង្វែង
Sustainable forest management to ensure a long-term supply of resources
បរិមាណ និង ទំហំនៃការធ្វើប្រតិបត្តិការអាជីវកម្មសមស្របដើម្បី
រក្សាតុល្យភាពរវាងកំរិតពាណិជ្ជកម្ម និងនិរន្តរភាពធនធានព្រៃឈើ
Number and size of operations adequate to balance commercial scale and resource sustainability

## គំនូសបំព្រួញទី ៤


ដំណាក់កាលដំបូងគឺការប្រមូលទិន្នន័យមូលដ្ឋានចាំបាច់
First stage is the collection of necessary baseline data
ព្រៃបំរុងទុកដែលរក្សាបាននូវប្រព័ន្ធ
អេកូឡូស៊ីព្រៃឈើទូទាំងដែនធម្មជាតិរបស់វា
Reserves that maintain forest ecosystems
throughout their natural range
ព្រៃបំរុងទុកដែលរក្សាបាននូវដំណើរការអេកូឡូស៊ី
ជំរកសត្វ និង រុក្ខជាតិ
Reserves that maintain ecological
processes and habitats
តើអ្វីខ្លះជាតំរូវការដើម្បីឱ្យមានប្រព័ន្ធព្រៃបំរុងទុកដែលមានលក្ខណៈជាតំណាងទូទៅ និង គ្រប់គ្រាន់ ?
What is required to have a comprehensive, adequate and
representative reserve system?
ព្រៃបំរុងទុកដែលរក្សាបាននូវវិសាលភាព
សេនេទិចចំរុះ (នានាភាពនៃសេនេទិច)
Reserves that maintain the range
of genetic diversity
ព្រៃបំរុងទុកដែលរក្សាបាននូវបណ្តុំការៈដែលអាចស្ថិតស្ថេរ
នៃប្រភេទរុក្ខជាតិក្នុងស្រុក នៅទូទាំងដែនធម្មជាតិរបស់វា
Reserves that maintain the viable populations of
native species throughout their natural range


Biological considerations
Political considerations
Social/cultural considerations
Decide on the size of management areas and their logical boundaries
Geographical considerations
Administrative considerations
How do we balance a viable forest industry and a comprehensive, adequate and representative reserve system?
Within management areas
Consider national and regional requirements
Inventory
Code of Practice
Determine area required as reserves
Determine net area available for commercial forest operations
Rare and endangered species
Aesthetic and cultural values
Allowable sustainable cut
Minimum commercial cut
Biodiversity
Overall management priorities

### ១-១- ក្របខ័ណ្ឌគោលនយោបាយព្រៃឈើ

ក្របខ័ណ្ឌនយោបាយព្រៃឈើមួយដែលសមស្រប គឺជាមូលដ្ឋានសំរាប់អនុវត្តកម្មវិធីគ្រប់គ្រងព្រៃឈើ និង ការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាព ។ នយោបាយព្រៃឈើជាតិ គួរមានផ្នែកមួយចែងពីនយោបាយប្រើប្រាស់ដី ដែលនឹងនាំឱ្យមាននូវតុល្យភាពរវាងការប្រើប្រាស់ និង ការអភិរក្សព្រៃឈើជាមួយកសិកម្ម និង ការប្រើប្រាស់ដីផ្សេងទៀត ។

ទិដ្ឋភាពសំខាន់ៗនៃនយោបាយព្រៃឈើជាតិ យ៉ាងហោចណាស់ក៏ត្រូវរួមបញ្ចូលនូវ:

- សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដែលអាស្រ័យលើការធានាសិទ្ធិកាន់កាប់ដីរយៈពេលវែងសំរាប់គ្រប់ភាគីពាក់ព័ន្ធ
- វិធានការម៉ឺងម៉ាត់ និង មិនរួញរាដើម្បីបង្ក្រាបរាល់សកម្មភាពកាប់ឈើ ការបរបាញ់ ការចាប់សត្វ និងការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់
- ការវាយតំលៃធនធានព្រៃឈើជាតិ ដើម្បីពង្រឹងមូលដ្ឋាន ការការពារព្រៃឈើ ការប្រើប្រាស់ និង ទិដ្ឋភាពនៃការគ្រប់គ្រងព្រៃឈើ ផ្សេងទៀត សំរាប់រយៈពេលវែង
- ការកំណត់នីតិវិធី និង ដំណើរការដែលនឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការសំរេចចិត្តស្ដីពីការប្រើប្រាស់ដីបានសមហេតុផល និង មានតុល្យភាព
- ការបញ្ជាក់ច្បាស់លាស់ពីនីតិវិធីស្របច្បាប់ ដើម្បីធានាប្រសិទ្ធិភាពនៃការតាមដានការគ្រប់គ្រងព្រៃឈើ និង ការរៀបចំឱ្យមានការអនុវត្តន៍តាមកិច្ចព្រមព្រៀង និង កិច្ចសន្យានានា
- ការទាញយកផលចំណូលជាអតិបរមាសំរាប់រាជរដ្ឋាភិបាលកម្ពុជា ពីការលក់ឈើហ៊ុប និង ផលិតផលព្រៃឈើផ្សេងទៀត
- ការអភិរក្សតំបន់តំណាងជីវៈចំរុះ ក្នុងព្រៃឈើប្រទេសកម្ពុជា ។

### ១-២- ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានព្រៃឈើប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព

ការគ្រប់គ្រង និង ការប្រើប្រាស់ធនធានព្រៃឈើប្រទេសកម្ពុជា នឹងផ្អែកលើគោលការណ៍សំខាន់ៗដូចតទៅ:

- ការគ្រប់គ្រងព្រៃធម្មជាតិរបស់ប្រទេសប្រកបដោយនិរន្តរភាព គឺជាវិភាគទានមួយដ៏សំខាន់បំផុតរបស់វិស័យព្រៃឈើចំពោះកម្មវិធីអភិវឌ្ឍន៍ជាតិ ដោយសារតែសក្ដានុពលភាព និង លទ្ធភាពធនធានព្រៃឈើក្នុងការបង្កើតចំណូលហិរញ្ញវត្ថុជាប្រចាំ ការផ្ដល់ការងារយូរអង្វែងដល់ប្រជាជន ការបំពេញសេចក្ដីប្រាថ្នាដ៏ច្រើននៃសហគមន៍មូលដ្ឋាន និង ការឆ្លើយតបនឹងតំរូវការ បរិស្ថាន វប្បធម៌ និង មនុស្សនាពេលបច្ចុប្បន្ន និង ពេលអនាគត
- ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព នឹងក្រសោបនូវសកម្មភាពមានតុល្យភាព និង ទូលំទូលាយទាំងឡាយដែលរួមបញ្ចូលនូវផែនការគ្រប់គ្រងរយៈពេលវែង និងរយៈពេលខ្លី ការធ្វើនិទស្សន៍ទិន្នផល ការដាក់បញ្ញត្តិ និងត្រួតពិនិត្យរុក្ខវប្បកម្ម និង ការការពារព្រៃឈើប្រកបដោយប្រសិទ្ធិភាព ។ ការប្រមូលផលព្រៃឈើ គឺជាផ្នែកមួយនៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដែលមិនមែនជាសកម្មភាពដាច់ដោយឡែកឬ ពុំមានការទាក់ទង និងការគ្រប់គ្រងឡើយ
- ក្នុងឋានៈជាទីភ្នាក់ងាររាជរដ្ឋាភិបាលដែលមានសមត្ថកិច្ចក្នុងវិស័យព្រៃឈើ នាយកដ្ឋានរុក្ខា-ប្រមាញ់ មានតួនាទីចំបង ក្នុងការដាក់បទបញ្ជា និងត្រួតពិនិត្យការការពារ និង គ្រប់គ្រងព្រៃឈើដែលជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ។

## ១-៣- សម្បត្តិព្រៃឈើអចិន្ត្រៃយ៍

សមាសភាគជាមូលដ្ឋាននៃគោលនយោបាយព្រៃឈើជាតិ គឺជាការកំណត់អត្តសញ្ញាណសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដែលរួមមានព្រៃឈើស្ថិតក្រោមកម្មសិទ្ធគ្រប់ប្រភេទ ដែលផ្អែកលើការធានាសិទ្ធិកាន់កាប់ព្រៃឈើរយៈពេលវែងសំរាប់ព្រៃសម្បទាន សហគមន៍មូលដ្ឋាន និង អ្នកប្រើប្រាស់ព្រៃឈើដទៃទៀត។ បើសិនជាគ្មានការកំណត់នូវសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ទេនោះ គេមិនអាចធ្វើផែនការគ្រប់គ្រង ព្រៃឈើអោយមាននិរន្តរភាព ឬ ធ្វើឱ្យកម្មវិធីគ្រប់គ្រងប្រកបដោយប្រសិទ្ធិភាពបានឡើយ ជាពិសេសការការពារព្រៃឈើ និង ការត្រួតពិនិត្យការប្រមូលផលព្រៃឈើ។

## ១-៤- ការការពារព្រៃឈើ

ការការពារព្រៃឈើមានសារៈសំខាន់ជាមូលដ្ឋាន ជាពិសេសលើការទប់ស្កាត់ការចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មព្រៃឈើច្រើនហួសហេតុ និង ការធ្វើអាជីវកម្មល្មើសច្បាប់ ។ សារៈសំខាន់ជាមូលដ្ឋាននៃការការពារព្រៃឈើមានដូចតទៅ :

- ដើម្បីរក្សាបូរណភាពនៃប្រព័ន្ធអេកូឡូស៊ី (ecological integrity) ព្រៃឈើ និង ដើម្បីរក្សាលទ្ធភាពផ្តល់ផលនៃធនធានព្រៃឈើ
- ដើម្បីរក្សាសមត្ថភាពនៃប្រព័ន្ធអេកូឡូស៊ីព្រៃឈើក្នុងការបន្តពូជដោយធម្មជាតិ និង ធានាថាប្រភពគ្រាប់ពូជនៃពពួកដើមឈើនៅក្នុងប្រព័ន្ធអេកូឡូស៊ីនេះត្រូវបានរក្សាទុកព្រមទាំងធានាថាដី និង ការបំផ្លាញរុក្ខជាតិស្ថិតក្នុងកំរិតទាបបំផុត
- ដើម្បីការពារសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ពីការរំលោភបំពាន ការប្រើប្រាស់មិនសមរម្យ ការបំផ្លាញ ឬ ការលួចផលិតផលឈើមានតំលៃ ។

## ១-៥- ព្រៃសម្បទាន

ការគ្រប់គ្រង និងការប្រើប្រាស់ធនធានព្រៃឈើធម្មជាតិមានលក្ខណៈពាណិជ្ជកម្ម អាស្រ័យលើការចាត់តាំង និង ការគ្រប់គ្រងតាមបែបសម្បទាន។ នេះគឺជាប្រព័ន្ធផ្តល់សិទ្ធិកាន់កាប់ដែលរាជរដ្ឋាភិបាលបានធ្វើការជ្រើសរើស ដើម្បីប្រើប្រាស់ និងគ្រប់គ្រងធនធានព្រៃឈើរបស់ជាតិ ។ ក្រោមប្រព័ន្ធព្រៃសម្បទាន ក្រុមហ៊ុនឯកជនអាចត្រូវបានផ្តល់នូវផ្ទៃដីព្រៃឈើជាកំណត់ណាមួយ និងសិទ្ធិប្រមូលផល ព្រមទាំងសិទ្ធគ្រប់គ្រងព្រៃឈើសំរាប់រយៈពេលជាកំណត់មួយស្របទៅតាមតំរូវការច្បាប់ និង កិច្ចសន្យា ។ ព្រៃសម្បទានិក នឹងទទួលខុសត្រូវលើការងារ គ្រប់គ្រងជាកំណត់នានាដែលរួមបញ្ចូលទាំងការធ្វើផែនការ ការការពារព្រៃឈើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង ការបង់ថ្លៃកាតព្វកិច្ចនានា ។ ផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន នឹងត្រូវបានការពារតាមរយៈការធ្វើផែនការសមស្រប និង ការរៀបចំ ចេញលិខិតអនុញ្ញាតទាំងឡាយ ។

## ១-៦- ការធ្វើផែនការគ្រប់គ្រង

ការទទួលខុសត្រូវលើការធ្វើផែនការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែង មធ្យម ប្រចាំឆ្នាំ នឹងអាស្រ័យលើព្រៃសម្បទានិក។ ផែនការគ្រប់គ្រងប្រចាំឆ្នាំ រយៈពេលមធ្យម និង រយៈពេលវែង នឹងបកស្រាយបញ្ចូលនយោបាយព្រៃឈើជាតិទៅក្នុងកម្មវិធីដែលមានការរៀបចំយ៉ាងហ្មត់ចត់ និង មានការសំរបសំរួលយ៉ាងល្អ ។ ផែនការនឹងដាក់ចុះនូវបទបញ្ញត្តិការពារការធ្វើសារពើភ័ណ្ឌ ការកំណត់ទិន្នផល ការប្រមូលផលព្រៃឈើ រុក្ខវប្បកម្ម ការអភិរក្សជីវៈចំរុះ និង ទីជំរាល ការការពារផលប្រយោជន៍សហគមន៍មូលដ្ឋាន ការតាមដានត្រួតពិនិត្យ និង ការប្រតិបត្តិការព្រៃឈើផ្សេងៗទៀត ដែលបញ្ជាក់ច្បាស់ពីគោលដៅ សកម្មភាព និង ការរៀបចំការត្រួតពិនិត្យ ។

ការធ្វើផែនការ និង ការរៀបចំប្រតិបត្តិការអាជីវកម្មព្រៃឈើ រួមមាន ៣ ដំណាក់កាលដូចខាងក្រោម :

ក- ការធ្វើផែនការរយៈពេលវែង សំរាប់គ្រប់គ្រងព្រៃសម្បទានទាំងមូល ។ ផែនការនេះរៀបចំឡើងសំរាប់ខួបអាជីវកម្ម រយៈពេលពី ២០-៣០ឆ្នាំ ។

ខ- ការធ្វើផែនការរយៈពេលមធ្យម សំរាប់អនុតំបន់ ផែនការនេះរៀបចំឡើងសំរាប់ប្រតិបត្តិការរយៈពេល ៣-៦ ឆ្នាំ ។

គ- ការធ្វើផែនការប្រចាំឆ្នាំ សំរាប់គ្រប់គ្រងកិច្ចគុប និង ប្លុក គឺផ្តោតទៅលើការធ្វើផែនការផ្អែកលើលទ្ធភាពផ្តល់ផល សំរាប់រយៈពេល ១ ឆ្នាំ ហើយផ្ទៃដីព្រៃគុប ត្រូវបានបែងចែកជាប្លុកអាជីវកម្ម ដើម្បីប្រើប្រាស់សំរាប់ត្រួតពិនិត្យ និង តាមដានឃ្លាំមើលប្រតិបត្តិការប្រមូលផលព្រៃឈើលើទីតាំងព្រៃគុបផ្ទាល់ ហើយផែនការទាំងនេះ នឹង ផ្អែកលើ យុទ្ធសាស្ត្រនៃការគ្រប់គ្រងព្រៃសម្បទានរយៈពេល វែង និង មធ្យម ។

តារាងទី១ : ប្រព័ន្ធនៃការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន តាមលំដាប់ថ្នាក់ :

| កំរិតនៃការគ្រប់គ្រង | | រយៈពេល | កត្តាគន្លឹះនៃ ការគ្រប់គ្រងព្រៃសម្បទាន |
|---|---|---|---|
| បញ្ហាជាយុទ្ធសាស្ត្រ | កំរិតជាតិ | >៣០ឆ្នាំ | ការអភិរក្ស និង ការការពារផ្អែកលើនយោបាយអំពូរឈើ |
| | កំរិតខេត្ត | >២៥ឆ្នាំ | ផែនការអភិវឌ្ឍន៍វិស័យអំពូរឈើ |
| ប្រតិបត្តិការ | ព្រៃសម្បទាន | ២០-៣០ឆ្នាំ | ១-មុខងារនៃការគ្រប់គ្រង-សមាសភាគរបស់ផែនការ<br>- គោលនយោបាយ និង គោលបំណង<br>- កម្មវត្ថុនៃការគ្រប់គ្រង<br>- ការអធិប្បាយពីប្រវត្តិព្រៃឈើ<br>- ការធ្វើសារពើភ័ណ្ឌធនធានព្រៃឈើ<br>- ការកំណត់តំបន់ និង ស្រទាប់ព្រៃ<br>- ការគណនាទិន្នផលធនធានព្រៃឈើ<br>- ផ្លូវមេ ស្ពាន និង របនាសម្ព័ន្ធ<br>- ការវាយតំលៃ និង ការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និង សង្គម<br>- ការតាមដាន និង ត្រួតពិនិត្យឡើងវិញ |
| | អនុតំបន់ | ៣-៦ ឆ្នាំ | ២- មុខងារនៃការគ្រប់គ្រង-សមាសភាគរបស់ផែនការ<br>- ការបែងចែកតំបន់ព្រៃឈើលំអិតទៅតាមមុខងារព្រៃឈើ<br>- សារពើភ័ណ្ឌព្រៃឈើ និង គណនាធនធានតាមគុប<br>- ការធ្វើផែនការវិស្វកម្មព្រៃឈើ<br>- ការកំណត់ការគ្រប់គ្រងព្រៃឈើ<br>- វិធានការប្រឹក្សា និង កាត់បន្ថយ បញ្ហាសង្គម និង បរិស្ថាន<br>- ការធ្វើសេចក្តីព្រាង និង កំណត់ព្រំប្រទល់<br>- ការគ្រប់គ្រងតំបន់ គ្រប់គ្រងពិសេស<br>- ការកំណត់ទីតាំង និង ការបណ្តុះបណ្តាល<br>- ការប្រតិបត្តិការងារគ្រប់គ្រងព្រៃឈើ<br>- ការវិភាគហិរញ្ញវត្ថុ<br>- ការតាមដាន និង ត្រួតពិនិត្យឡើងវិញ |
| | ផែនការ គុប និង ប្លុក | ការគ្រោងរយៈពេលក្នុងឆ្នាំទីមួយ១ | ៣-មុខងារនៃការគ្រប់គ្រងៈសមាសភាគនៃការអនុវត្តន៍ និងការត្រួតពិនិត្យ<br>- ការពណ៌នាអំពីស្ថានភាពព្រៃគុប និង ផែនការប្រមូលផល<br>- ធ្វើការបង់លេខ និង ដៅឈើ ១០០%<br>- ការពណ៌នាបច្ចេកទេស ការស្ថាបនាផ្លូវ ស្ពាន និងផ្លូវអូសទាញ<br>- បញ្ញត្តិសំរាប់សកម្មភាពគ្រប់គ្រងព្រៃឈើ<br>- ការគ្រប់គ្រងធនធានព្រៃឈើដែលមានផលប៉ះពាល់បរិស្ថានកំរិតទាប<br>- ការកំណត់ទិន្នផលទៅតាមបរិមាណឈើមានទំហំអប្បបរមា (អាយុ) អនុញ្ញាតអោយកាប់ ។<br>- ការការពារព្រៃឈើ<br>- ការធ្វើសហប្រតិបត្តិការជាមួយសហគមន៍រស់នៅពឹងផ្អែកលើព្រៃឈើ<br>- ការធ្វើអធិការកិច្ចធនធានព្រៃឈើ (ការតាមដានត្រួតពិនិត្យ និង រាយការណ៍ធៀបនឹងបញ្ញត្តិ ដែលមានចែងក្នុងផែនការគ្រប់គ្រង)<br>- ការត្រួតពិនិត្យការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនព្រៃសម្បទានដល់ទីកន្លែងដោយនាយកដ្ឋានរុក្ខា-ប្រមាញ់<br>- ការសើរើ និងត្រួតពិនិត្យឡើងវិញលើផែនការគ្រប់គ្រងយ៉ាងទៀងទាត់ និង តាមដំណាក់កាល<br>- តាមដាន និង ត្រួតពិនិត្យ វាយតំលៃ ។ |

ផែនការគ្រប់គ្រងត្រូវបញ្ចូលតែពត៌មានណាដែលចាំបាច់ដើម្បីសំរេចគោលដៅផែនការ ។ ការបញ្ចូលបន្ថែមពត៌មានច្រើនជាងសេចក្តីត្រូវការ នឹងបណ្តាលឱ្យមានភាពច្រំដែល ហើយត្រូវចំណាយធនធានមានតំលៃជាច្រើនក្នុងអំឡុងពេលនៃដំណើរការធ្វើផែនការ ។

កំរិតខុសគ្នានៃការធ្វើផែនការគ្រប់គ្រង អាចប្រដូចបានទៅនឹងឡូតិ៍ និងអនុឡូតិ៍ត្រួតលើគ្នាក្នុងប្រព័ន្ធសារពើភ័ណ្ឌព្រៃឈើ ។ សំរាប់ផែនការទ្រង់ទ្រាយធំ (ផែនការព្រៃសម្បទាន) គឺត្រូវបញ្ចូលតែពត៌មានមូលដ្ឋានចាំបាច់ប៉ុណ្ណោះ ។ នៅពេលដែលទំហំនៃការធ្វើផែនការកាន់តែតូច កំរិតពិស្តារនៃពត៌មានដែលត្រូវបញ្ចូលក្នុងផែនការគឺកាន់តែកើនឡើង ។

ដើម្បីអនុវត្តប្រព័ន្ធនៃការធ្វើផែនការគ្រប់គ្រងព្រៃឈើ ចាំបាច់ត្រូវ :

១- យល់ពីកំរិតចាំបាច់នៃការធ្វើផែនការ

២- ជ្រើសរើសប្រធានបទទាក់ទង ដើម្បីដាក់បញ្ចូលទៅក្នុងកំរិតនីមួយៗនៃការធ្វើផែនការ

៣- រៀបដាក់បញ្ចូលតាមលំដាប់ នូវប្រធានបទដែលបានជ្រើសរើស ទៅក្នុងកំរិតនីមួយៗនៃផែនការក្នុងទំរង់ដែលបានបង្កើតមុនជាស្រេច ។

## ១-៧ ការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន និង វដ្តនៃការអនុវត្តន៍ផែនការ

ការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន និង វដ្តនៃការអនុវត្តន៍ផែនការ មានទំនាក់ទំនងលើធាតុគន្លឹះនៃការធ្វើផែនការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែងជាមួយនឹងការធ្វើផែនការប្រចាំឆ្នាំ និង ការធ្វើប្រតិបត្តិការប្រមូលផលព្រៃឈើ ដែលនឹងត្រូវបានសំរេចហើយយកទៅអនុវត្តជាផ្នែកមួយនៃនយោបាយព្រៃឈើជាតិ ។ ធាតុនៃការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន មានបង្ហាញជូនក្នុង រូបភាពទី១ និង ត្រូវបានពន្យល់ ដូចខាងក្រោម :

ពេញមួយវដ្តនៃការគ្រប់គ្រង នាយកដ្ឋានរុក្ខា-ប្រមាញ់ និង ភាគីពាក់ព័ន្ធផ្សេងទៀត នឹងធ្វើការត្រួតពិនិត្យព្រៃសម្បទានិក ដោយការសើរើត្រួតពិនិត្យឡើងវិញយ៉ាងហ្មត់ចត់នូវការអនុវត្តន៍ផែនការ ការផ្តល់លិខិតអនុញ្ញាត និង ការតាមដានឃ្លាំមើល ហើយនឹងវាយតម្លៃលើការអនុវត្តន៍របស់ព្រៃសម្បទានិកធៀបនឹងផែនការ និង គោលនយោបាយព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ការអនុវត្តន៍បានទៅតាមតំរូវការខាងលើរបស់រាជរដ្ឋាភិបាល គឺជាលក្ខខណ្ឌដើម្បីឱ្យមានការអនុវត្តន៍បន្តទៅគ្រប់ដំណាក់កាលនៃវដ្តផែនការ ប៉ុន្តែវាក៏អាស្រ័យទៅនឹងនីតិវិធីនៃការដោះស្រាយជំលោះជាក់លាក់នានាផងដែរ ។

រូបភាព១ ការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន និង វដ្តនៃការអនុវត្តន៍



## ២- ការកំណត់ព្រៃសម្បទាន

ព្រៃសម្បទានត្រូវបានកំណត់ឡើងតាមវិធីសមស្របដូចមានចែងខាងក្រោម :

- មានតែព្រៃឈើដែលបានពីមូលដ្ឋាននៃការកំណត់តំបន់ព្រៃឈើទូលំទូលាយ និង ដែលអាចត្រូវបានគ្រប់គ្រងក្នុង លក្ខណៈនិរន្តរភាព និង លើមូលដ្ឋានចីរភាពសេដ្ឋកិច្ចប៉ុណ្ណោះ ដែលនឹងត្រូវចាត់បញ្ចូលទៅក្នុងព្រៃសម្បទាន
- ដីព្រៃឈើនៃព្រៃសម្បទានដែលកំពុងធ្វើអាជីវកម្ម ឬ ដីព្រៃឈើដែលត្រូវបានការពារសំរាប់ផលប្រយោជន៍បរិស្ថាន និងសង្គម ឬរក្សាទុកសំរាប់ការប្រើប្រាស់ក្នុងលក្ខណៈពាណិជ្ជកម្មផ្សេងទៀត នឹង មិនត្រូវបានចាត់បញ្ចូលទៅក្នុងព្រៃសម្បទានបង្កើតថ្មីឡើយ
- ទំហំនៃព្រៃសម្បទានមួយទាក់ទងទៅនឹង :
  + គោលដៅនៃការអភិវឌ្ឍន៍ថ្នាក់ជាតិ និង ថ្នាក់ខេត្ត
  + លទ្ធភាពរបស់ព្រៃសម្បទានិក ក្នុងការការពារព្រៃសម្បទានប្រកបដោយប្រសិទ្ធភាព និងស្ថេរភាព
  + លទ្ធភាពផលិតនៃធនធានព្រៃឈើដែលអាចផ្គត់ផ្គង់ឈើជាបន្តសំរាប់ឧស្សាហកម្មកែច្នៃ ដែលសមស្របជាមួយ នឹងសំណូមពរទីផ្សាររបស់ព្រៃសម្បទានិក
  + សមត្ថភាពនៃព្រៃសម្បទានិកក្នុងការរួមចំណែកដល់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ ។

### ២-១- ថេរវេលានៃកិច្ចព្រមព្រៀងព្រៃសម្បទាន

- កិច្ចព្រមព្រៀងព្រៃសម្បទានត្រូវកំណត់មិនលើសពីរយៈពេល ៣០ ឆ្នាំឡើយ។ ផ្អែកលើមូលដ្ឋានបច្ចេកទេស នេះគឺជាវដ្តនៃការធ្វើអាជីវកម្មព្រៃឈើសំរាប់ប្រភេទឈើដែលមានលក្ខណៈលុប
- ថេរវេលាសម្បទាន ៣០ ឆ្នាំនឹងអាចឱ្យព្រៃសម្បទានិកមានលទ្ធភាពប្រើប្រាស់ធនធានព្រៃឈើក្នុងរយៈពេលមួយដែលត្រូវបានពិចារណាថាគ្រប់គ្រាន់ ដើម្បីឱ្យព្រៃសម្បទានិកមានទំនុកចិត្ត ចំពោះការវិនិយោគលើការធ្វើផែនការព្រៃឈើ ការកសាងហេដ្ឋារចនាសម្ព័ន្ធកិច្ចដំណើរការឧស្សាហកម្មកែច្នៃឈើការការពារព្រៃឈើ និង ផ្នែកផ្សេងទៀតដែលអាចធ្វើការរំលោះបានវិញ ។

### ២-២- ព្រំប្រទល់ព្រៃសម្បទាន

- បើអាចធ្វើទៅបានព្រំប្រទល់ធម្មជាតិដែលមានលក្ខណៈសំគាល់ងាយស្រួល និងត្រូវបានប្រើប្រាស់ដើម្បីកំណត់ព្រំប្រទល់ព្រៃសម្បទាន ដូចជា ទន្លេ ស្ទឹង ចង្អូរ ។ ផ្លូវអចិន្ត្រៃយ៍ក៏អាចប្រើធ្វើជាព្រំប្រទល់ព្រៃសម្បទានបានដែរ
- ករណីពុំមានព្រំប្រទល់ធម្មជាតិច្បាស់លាស់ ព្រំប្រទល់ព្រៃសម្បទានត្រូវកំណត់តាមបន្ទាត់ត្រង់ ដែលមានទិសជើង-ត្បូង និង កើត-លិច ដើម្បីអាចបង្ហាញជាក្តួរដោនេភូមិសាស្ត្រលើផែនទី។ កាច់ជ្រុងនៃព្រំប្រទល់តាមបន្ទាត់ត្រង់គួរលៃយ៉ាងណាអោយមានចំនួនតិចបំផុត ។ ព្រំប្រទល់ជាបន្ទាត់ត្រង់ និងត្រូវកំណត់ឡើងដោយបង្គោលសំគាល់ ។

## ៣- ការផ្តល់ព្រៃសម្បទានតាមការបេញថ្លៃជាសាធារណៈ

ការដេញថ្លៃដែលមានលក្ខណៈប្រកួតប្រជែង គឺជាយន្តការអាចទទួលយកបានខាងពាណិជ្ជកម្ម សំរាប់ធ្វើការផ្តល់ព្រៃសម្បទាន ឬ សិទ្ធិនៃការប្រមូលផលព្រៃឈើ និង សិទ្ធិនៃការគ្រប់គ្រងព្រៃឈើ។ រាជរដ្ឋាភិបាលនឹងអនុវត្តគោលការណ៍នេះនៅពេលដែលមានការផ្សាយពាណិជ្ជកម្មពីការលក់សិទ្ធិក្នុងការប្រមូលផលព្រៃឈើ និង សិទ្ធិគ្រប់គ្រងព្រៃសម្បទានដែលបានសើរើឡើងវិញ ឬព្រៃសម្បទានថ្មី ។

ជាទូទៅជំហានដំបូងនៃដំណើរការដេញថ្លៃជាសាធារណៈ ត្រូវអនុវត្តទៅតាមៈ

- ការកំណត់បង្ហាញពីព្រំប្រទល់ព្រៃឈើជាក់ស្តែងដែលគ្រោងដាក់ដេញថ្លៃជាព្រៃសម្បទាន
- ការកំណត់បញ្ជាក់ពីធនធានព្រៃឈើ (តាមការធ្វើសារពើភ័ណ្ឌជាមុន) ដែលរួមមានព្រៃសម្បទានថ្មី ឬព្រៃសម្បទានដែលបាន ស៊េរីស្របតាមគោលការណ៍ណែនាំស្តីពីការកំណត់ព្រៃសម្បទាន
- ការរៀបចំឯកសារដែលពណ៌នាលំអិត ពីលក្ខណៈសម្បត្តិនៃព្រៃសម្បទាន គ្រប់ធនធានទាំងអស់ដែលព្រៃសម្បទានមាន និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងដែលជាតំរូវការចាំបាច់សំរាប់ព្រៃសម្បទានិក ដោយរាប់បញ្ចូលការរៀបចំគ្រប់ជ្រុងជ្រោយដើម្បីការការពារព្រៃឈើ ការគ្រប់គ្រងរុក្ខវប្បកម្ម ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់ការងារ ការអភិវឌ្ឍន៍ផ្នែកឧស្សាហកម្ម និង ធនធានមនុស្ស
- ការផ្សព្វផ្សាយជាសាធារណៈពីសំណើព្រៃសម្បទានដែលដាក់អោយដេញថ្លៃសំរាប់ការគ្រប់គ្រងរយៈពេលវែង និង សិទ្ធិប្រមូលផលព្រៃឈើ ដោយបញ្ជាក់ពីលក្ខខណ្ឌទាំងឡាយ ដែលអនាគតព្រៃសម្បទានិកត្រូវបំពេញរាប់បញ្ចូលទាំងការដាក់ស្នើដោយឡែកនូវបែបបទបច្ចេកទេស និង បរិមាណទឹកប្រាក់សំរាប់ដេញថ្លៃ
- ពាក្យស្នើសុំដេញថ្លៃត្រូវបានរក្សាទុកដោយបិទជិត រហូតដល់កាលបរិច្ឆេទ "ឈប់ទទួលពាក្យដេញថ្លៃ" ។

សេចក្តីលំអិតស្តីពីការកំណត់ផ្តល់ព្រៃសម្បទានតាមការដេញថ្លៃជាសាធារណៈ មានចែងនៅក្នុងអនុក្រឹត្យលេខ ០៥ អនុក្រ.បក. ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងព្រៃសម្បទាន។

## ៤- ការបង្កើតផែនការគ្រប់គ្រងព្រៃឈើរយៈពេលវែង

តំរូវការមួយក្នុងការផ្តល់ព្រៃសម្បទាន គឺព្រៃសម្បទានិកត្រូវរៀបចំគំរោងស្នើដែលមានលក្ខណៈច្បាស់លាស់ និង មានគុណភាព សំរាប់ការគ្រប់គ្រង និង ការប្រើប្រាស់ព្រៃសម្បទាន ក្នុងទំរង់ផែនការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែង ។

### ៤-១- ទិដ្ឋភាពទូលទៅនៃការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន

ការធ្វើផែនការ គឺជាដំណើរការដំសកម្មដែលទាមទារនូវការគិតគូរយ៉ាងប្រុងប្រយ័ត្ន និង ល្អិតល្អន់ពីអ្វីដែលអាច ឬនឹងកើតមានឡើងក្នុងពេលអនាគត ។ ការពិចារណាសំខាន់ៗមានដូចតទៅ :

- ការធ្វើផែនការគឺជាផ្នែកមួយសំរាប់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងព្រៃឈើទាំងមូល និង ជាមូលដ្ឋានលើការសំរេចគោលដៅរយៈពេលវែង គោលបំណង និង ជាការបង្កើតឡើងនូវបណ្តាទិសដៅពិតប្រាកដ។ វាក៏ទាក់ទងផងដែរនឹងការដាក់ចុះនូវវិធានការដែលត្រូវប្រកាន់យកដើម្បីសំរេចបាននូវគោលដៅ និង គោលបំណងទាំងនោះ
- ផែនការនឹងត្រូវបានរៀបចំឱ្យមានទំនាក់ទំនងលំអិតច្បាស់លាស់ និង ឆ្លើយតបទៅនឹងគោលដៅ និង គោលបំណងដែលត្រូវបានកំណត់ ។ ផែនការត្រូវមានភាពរលូន ដើម្បីដោះស្រាយព្រឹត្តិការណ៍ដែលអាចកើតឡើងដោយឥតគ្រោងទុក
- ផែនការនឹងត្រូវបានរៀបចំដោយអនុលោមតាមក្រឹត្យច្បាប់ និង បទបញ្ញត្តិទាំងឡាយ និង ជាមូលដ្ឋានសំរាប់ការអនុវត្តន៍គោលការណ៍ណែនាំ និង បទដ្ឋានបច្ចេកទេសរបស់នាយកដ្ឋានរុក្ខា-ប្រមាញ់
- ផែនការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែង នឹង បំពេញតាមគោលបំណងនៃការវាយតំលៃផលប៉ះពាល់បរិស្ថាន និង សង្គម
- ដំណើរនៃការធ្វើផែនការ ត្រូវតែលើកឡើងនូវបញ្ហាអតីតកាល ហើយផែនការត្រូវផ្តល់នូវដំណោះស្រាយដែលអាចអនុវត្តជាវិជ្ជមាន និង មានប្រសិទ្ធិភាពសេដ្ឋកិច្ច
- សំណើទាំងឡាយដែលឆ្លើយតបចំពោះ ការការពារធនធានព្រៃឈើប្រកបដោយប្រសិទ្ធិភាព រួមមានការកាប់ឈើដោយរំលោភ និង ការប្រមូលផលល្មើសច្បាប់

- ត្រូវធ្វើការសង្ខេបពីបញ្ហាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងជាបឋមទាំងឡាយ ដែលត្រូវបានរំពឹងថា នឹងមានឥទ្ធិពលលើការគ្រប់គ្រងព្រៃសម្បទានព្រោះថា ការវាយតំលៃលើបញ្ហាពាក់ព័ន្ធ និង ការគ្រប់គ្រងនៃពតិមានមូលដ្ឋានគឺជាចំណងទាក់ទង រវាងគោលបំណងផែនការ និង បញ្ញត្តិផែនការ
- ផែនការត្រូវតែចែងពីបទបញ្ញត្តិដែលត្រូវធ្វើការសើរើពិនិត្យឡើងវិញនៅឆ្នាំទី ១០ ដែលជាចំណុច ១/៣ នៃរយៈពេលផែនការ ២០-៣០ ឆ្នាំ
- ផែនការនឹងមិនត្រូវបានឯកភាពឡើយប្រសិនបើគ្មានកំណត់ពីតំរូវការនៃការតាមដានត្រួតពិនិត្យ និង ការធ្វើសេចក្តីរាយការណ៍ជាក់លាក់ទេនោះ ។ បញ្ញត្តិនានានៃផែនការត្រូវតែអាចវាស់ និងអាចត្រួតពិនិត្យបានយ៉ាងងាយស្រួល ។

### ៤-២- <u>ការកំណត់តំបន់ព្រៃឈើ</u>

ការកំណត់តំបន់ព្រៃឈើពាក់ព័ន្ធទៅនឹងការធ្វើអត្តសញ្ញាណនៃតំលៃលប់ (Predominant value) សំរាប់តំបន់ដីព្រៃឈើជាក់លាក់ដែលនឹងត្រូវរៀបចំតាមគោលបំណងទាក់ទងទៅនឹងតំលៃលប់ទាំងនោះ ។ តាមរយៈការកំណត់តំបន់ ការដាក់បទបញ្ជា លើការគ្រប់គ្រងដីព្រៃឈើដែលមានតំលៃជាក់លាក់អាចត្រូវបានកំណត់យ៉ាងច្បាស់លាស់ ។ ការកំណត់តំបន់ គឺជាជំហានដ៏សំខាន់ ក្នុងការកំណត់ទីតាំងផ្ទៃដីផ្តល់ផលសុទ្ធសាធសំរាប់ព្រៃសម្បទាន ហើយត្រូវបានអនុវត្តជាមូលដ្ឋាននៃដំណើរការធ្វើផែនការព្រៃសម្បទានរយៈពេលវែង ។

ផ្ទៃដីផ្តល់ផលសុទ្ធសាធ ឬជាតំបន់ផលិតកម្មឈើ នឹងត្រូវបានកំណត់ដោយការដកផ្ទៃដីមិនផ្តល់ផលពីផ្ទៃដីសរុបនៃឯកតាព្រៃរៀបចំ ។ តំបន់ផលិតកម្មឈើនឹងបង្កើតបានមូលដ្ឋានផ្ទៃដី សំរាប់កំណត់បរិមាណឈើដែលអនុញ្ញាតឱ្យដកហូតប្រចាំឆ្នាំ ។

### ៤-៣- <u>គោលដៅ និង គោលបំណងនៃការគ្រប់គ្រងព្រៃឈើ</u>

អត្តសញ្ញាណកម្មនៃ<u>គោលដៅគ្រប់គ្រង</u> និង <u>គោលបំណងគ្រប់គ្រង</u> ដ៏ជាក់លាក់ស្របទៅនឹងអាទិភាពនៃនយោបាយសក្តានុភាពនៃធនធាន និង ឧបសគ្គ គឺជាមូលដ្ឋាននៃគោលការណ៍គ្រប់គ្រងព្រៃឈើ ហើយនឹងត្រូវបានយកទៅអនុវត្តក្នុងដំណើរនៃការធ្វើផែនការព្រៃសម្បទានទាំងអស់ ។

- គោលដៅគឺជាគោលបំណងរយៈពេលវែង និង អាចត្រូវបានកំណត់ចេញពីនយោបាយព្រៃឈើ ឬ ត្រូវបានកំណត់ថាជាលទ្ធផលចុងក្រោយនៃយុទ្ធសាស្ត្រ ដើម្បីសំរេចបានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។ គួរមានគោលដៅតែមួយប៉ុណ្ណោះ សំរាប់ព្រៃសម្បទានណាមួយ
- គោលបំណងគឺជាសកម្មភាពទាំងឡាយដែលអាចវាស់បាន ដែលបង្ហាញនូវលទ្ធផលជាក់លាក់ ដើម្បីឱ្យបានសំរេចក្នុងអំឡុងពេលមួយកំណត់ ។ គោលបំណងមួយចំនួនអាចត្រូវកំណត់ និង បញ្ជាក់ន័យច្បាស់ក្នុងផែនការមួយ ។

គោលបំណងនីមួយៗគួរបញ្ជាក់ឱ្យបានច្បាស់លាស់ពី:

- សកម្មភាពអ្វីដែលនឹងត្រូវអនុវត្ត
- សកម្មភាពនេះ នឹងកើតឡើងនៅកន្លែងណា
- នរណាជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍
- នៅពេលណាដែលសកម្មភាពត្រូវបានអនុវត្ត និង ត្រូវបានបញ្ចប់
- តើទិន្នន័យលទ្ធផលដែលពាក់ព័ន្ធមានប៉ុន្មាន ឬ ចំនួនសេចក្តីរាយការណ៍ដែលជាក់លាក់មានប៉ុន្មាន

- គោលបំណងជាក់លាក់នៃផលិតកម្មឈើជាទូទៅត្រូវ :
  - ផ្តល់នូវគោលការណ៍ដ៏តឹងរឹងលើបរិមាណមាឌឈើហ៊ុបដែលអាចដកហូតបាន
  - បញ្ជាក់ពីលក្ខខណ្ឌ និង ផលវិបាកក្នុងការប្រមូលផលព្រៃឈើ ។

## ៤-៤- ការបែងចែកព្រៃសម្បទាន

ជំហានដ៏សំខាន់ក្នុងដំណើរការធ្វើផែនការគ្រប់គ្រងរយៈពេលវែង គឺជាការកំណត់ដ៏ជាក់លាក់មួយ នៃតួនាទីរបស់ ព្រៃសម្បទាន ព្រៃគុបប្រចាំឆ្នាំ និង ប្លុកអាជីវកម្មដែលបានគូរក្នុងផែនទីព្រៃសម្បទាន។ ការទទួលស្គាល់ និង ការកំណត់យ៉ាងច្បាស់លាស់ ពីតួនាទីព្រៃសម្បទានគឺជាការរួមចំណែកដោយផ្ទាល់ ចំពោះការបង្កើតឡើងនូវគោលបំណងនៃការគ្រប់គ្រង។

*ព្រៃសម្បទាន* គឺជាផ្នែកមួយនៃភូមិសាស្ត្រព្រៃឈើដែលបង្កើតជាមូលដ្ឋាន សំរាប់ការកំណត់តំបន់ និង ការធ្វើផែនការព្រៃឈើរយៈពេលវែង ជាពិសេសនាំទៅដល់ការកំណត់បរិមាណឈើអនុញ្ញាតឱ្យកាប់ហូត សំរាប់រយៈពេល ២០-៣០ ឆ្នាំ ។ ចំពោះវិសាលភាពនៃការអនុវត្តន៍ផ្ទៃដីព្រៃឈើដែលត្រូវរៀបចំសំរាប់គោលបំណងខុសៗគ្នា ឬ មានតំលៃខុសគ្នាច្បាស់លាស់ គួរត្រូវបានដាក់ជាតំបន់ដោយឡែកពីគ្នា ។

- តំបន់ព្រៃគួរមានប្រភេទព្រៃឯកសណ្ឋានជាទូទៅ
- នៅទីកន្លែងណាដែលអាចធ្វើទៅបាន ព្រំប្រទល់តំបន់គួរជាភូមិសាស្ត្រងាយស្រួលសំគាល់នៅលើទីវាល និង ត្រូវកំណត់ក្នុងផែនទីគ្រប់គ្រងព្រៃឈើ ។

*ព្រៃអនុតំបន់* គឺជាផ្នែកមួយនៃព្រៃសម្បទាន សំរាប់ការធ្វើផែនការរយៈពេលមធ្យម ៣-៦ ឆ្នាំ ។

- អនុតំបន់អាចមានពី ៣ ទៅ ៧ គុប អាស្រ័យទៅតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង
- ព្រំប្រទល់អនុតំបន់ គួរជាតំបន់ដែលមានលក្ខណៈភូមិសាស្ត្រងាយស្រួលសំគាល់ដូចជា : ស្ទឹង ព្រែក ផ្លូវ ដែលត្រូវបានកត់ត្រាទៅក្នុងផែនទីគ្រប់គ្រងព្រៃឈើ
- ការបង់លេខសំគាល់អនុតំបន់ គួរដាក់តាមលំដាប់លេខរៀងដោយចាប់ផ្តើមពីជំរុំ ឬ ទីចាត់ការក្នុងព្រៃសម្បទាន។ លេខ អនុតំបន់ មិនត្រូវផ្លាស់ប្តូរទេ។

*ព្រៃគុប* គឺជាផ្ទៃដីព្រៃឈើត្រូវបង្កើតជាមូលដ្ឋាននៃការធ្វើផែនការប្រមូលផលប្រចាំឆ្នាំនីមួយៗ ។ វាជាឯកតាភូមិសាស្ត្រងាយស្រួលកំណត់ សំរាប់ការធ្វើផែនការលំអិត ការដាក់បញ្ញត្តិ ការអនុវត្តន៍ការតាមដានត្រួតពិនិត្យ និង ជាមូលដ្ឋានសំរាប់កត់ត្រាជាអចិន្ត្រៃយ៍នូវរាល់ប្រតិបត្តិការអាជីវកម្មព្រៃឈើ។ ចំពោះវិសាលភាពនៃការអនុវត្តន៍ផ្ទៃដីព្រៃឈើ ដែលត្រូវបានរៀបចំសំរាប់គោលបំណងខុសៗគ្នា ឬ មានតំលៃខុសគ្នាច្បាស់លាស់ គួរត្រូវដាក់ព្រៃគុប ដាច់ដោយឡែកពីគ្នា ។

- ផ្ទៃដីព្រៃគុបអាចនៅចន្លោះពី ១០០០ ទៅ ៤០០០ ហិចតា
- ការកត់ត្រាពីសកម្មភាពរបស់ព្រៃគុប នឹងត្រូវបានរក្សាសំរាប់គោលបំណងនៃការធ្វើរបាយការណ៍ជាអចិន្ត្រៃយ៍នូវរាល់សកម្មភាពគ្រប់គ្រងព្រៃឈើទាំងអស់
- នៅទីកន្លែងណាដែលអាចធ្វើទៅបាន ព្រំប្រទល់ព្រៃគុបគួរជាតំបន់ដែលមានលក្ខណៈភូមិសាស្ត្រងាយស្រួលសំគាល់លើទីវាលកំណត់ដោយទន្លេ ស្ទឹង ជួរភ្នំ ជ្រោះ ផ្លូវអចិន្ត្រៃយ៍ក៏អាចប្រើជាព្រំប្រទល់ព្រៃគុបផងដែរ។ ព្រំប្រទល់ព្រៃគុបគួរត្រូវបានកត់ត្រាក្នុងគ្រប់ផែនទីគ្រប់គ្រងព្រៃឈើ
- ការដាក់លេខសំគាល់ព្រៃគុបគួរដាក់តាមលំដាប់លេខរៀងដោយចាប់ផ្តើមពីជំរុំ ឬទីចាត់ការក្នុងព្រៃសម្បទាន។ លេខព្រៃគុប មិនត្រូវផ្លាស់ប្តូរទេ ។

*ប្លុកអាជីវកម្ម* : គឺជាផ្នែកនៃការគ្រប់គ្រងតូចបំផុត និង មានតួនាទីជាឯកតាត្រួតពិនិត្យការកាប់ឈើក្នុងប្រតិបត្តិការប្រមូលផលព្រៃឈើ។ ផ្ទៃដីប្លុកគួរស្ថិតនៅចន្លោះពី ១០០ ទៅ ២០០ ហិកតា ។ ការគ្រប់គ្រងប្លុកត្រូវបានបញ្ជាក់ច្បាស់ក្នុង *ក្រមបច្ចេកទេសអនុវត្តប្រមូលផលព្រៃឈើ*។

## ៤-៥- ការធ្វើសារពើភ័ណ្ឌធនធានព្រៃឈើ

សារពើភ័ណ្ឌធនធានព្រៃឈើធ្វើឡើងដើម្បីកំណត់មាឌ ប្រភេទ គុណភាព សំរាប់ធ្វើផែនការប្រើប្រាស់ធនធានព្រៃឈើរយៈពេលវែង មធ្យម និង ប្រចាំឆ្នាំ និង សំរាប់ចាត់ស្មានមាឌឈើអប្បបរមា ដើម្បីផ្សព្វផ្សាយការដេញថ្លៃព្រៃសម្បទានជាសាធារណៈ ។ ផ្អែកលើគោលបំណងនៃការប្រើប្រាស់ធនធានព្រៃឈើដែលមានស្រាប់ សមាសភាព និង របាយ ព្រៃឈើ ការធ្វើសារពើភ័ណ្ឌធនធានអនុផលព្រៃឈើ ក៏អាចត្រូវអនុវត្តផងដែរ ។

ការធ្វើសារពើភ័ណ្ឌព្រៃឈើអាចមានច្រើនប្រភេទអាស្រ័យលើគោលបំណង និងតួនាទីដែលចង់បាន ប៉ុន្តែប្រភេទនីមួយៗត្រូវបានចាត់ថ្នាក់ដូចតទៅ:

- <u>សារពើភ័ណ្ឌសំរាប់ប្រមូលផលព្រៃឈើ</u>
  - \+ សារពើភ័ណ្ឌបុរេសម្បទាន គឺដើម្បីផ្តល់ការអធិប្បាយដ៏ទូលំទូលាយអំពីពត៌មានធនធានព្រៃឈើ ដើម្បីផ្សព្វផ្សាយឱ្យមានការចូលរួមដេញថ្លៃព្រៃសម្បទានជាសាធារណៈ
  - \+ សារពើភ័ណ្ឌសំរាប់ធ្វើផែនការគ្រប់គ្រង គឺដើម្បីផ្តល់ពត៌មានលំអិតគ្រប់គ្រាន់ និង សុក្រិត អំពីធនធានព្រៃឈើ ដើម្បីជំរុញឱ្យមានការបង្កើតឡើងនូវផែនការរយៈពេលវែងសំរាប់ព្រៃសម្បទានមួយ
  - \+ សារពើភ័ណ្ឌសំរាប់ការធ្វើផែនការមុនពេលប្រមូលផលព្រៃឈើ គឺដើម្បីផ្តល់ពត៌មានលំអិតស្តីពីទីតាំង សមាសភាព ប្រភេទ និងទំហំនៃដើមឈើដែលនឹងអនុញ្ញាតឱ្យដកហូត និង ឈើដែលត្រូវបន្សល់ទុក
  - \+ ការវាយតំលៃក្នុងពេល និង ក្រោយពេលប្រមូលផល គឺជាការត្រួតពិនិត្យដោយប្រព័ន្ធដែលបានអនុវត្តក្នុងពេល និង ក្រោយពេលប្រមូលផលព្រៃឈើ ដើម្បីកំណត់ពីកិរិតនៃការប្រមូលផលព្រៃឈើ តើស្របតាមផែនការប្រមូលផលព្រៃឈើ និង គោលបំណងឬទេ ។
- <u>សារពើភ័ណ្ឌសំរាប់ការគ្រប់គ្រង</u>

ការសិក្សាពីកំណើនលូតលាស់របស់ព្រៃឈើ ( ការធ្វើសារពើភ័ណ្ឌព្រៃឈើជាបន្តបន្ទាប់ ) គឺធ្វើឡើងក្នុងគោលបំណងប្រមូលផ្តុំឯកសារពត៌មានក្នុងរយៈពេលវែងអំពីការលូតលាស់ និង ដំណើរងាប់ទៅវិញនៃព្រៃឈើ ។

- \+ សារពើភ័ណ្ឌជីវៈចំរុះ គឺដើម្បីផ្តល់ពត៌មានពីប្រភេទផ្សេងៗ ចំនួនប្រភេទដែលមានវត្តមានក្នុងតំបន់ណាមួយ ។ ប៉ុន្តែសារពើភ័ណ្ឌនេះត្រូវបានពង្រីករហូតដល់ពត៌មានស្តីពីទំនាក់ទំនងនៃចំណាត់ថ្នាក់ប្រភេទ និង របាយរបស់វាទៅតាមភាពកម្រ និង ការប្រមូលផ្តុំក្នុងតំបន់តែមួយ
- \+ ការដាក់តាំងឡូត៍គំរូសំរាប់សិក្សា គឺដើម្បីផ្តល់ពត៌មានអំពីសក្តានុពលភាពនៃរុក្ខវប្បកម្មព្រៃឈើ បន្ទាប់ពីការប្រមូលផល
- \+ ការអង្កេតសិក្សាពីសង្គម គឺដើម្បីទទួលពត៌មានសំរាប់ជួយធ្វើផែនការសហគមន៍ជនបទនៅក្នុង ឬ ក្បែរព្រៃសម្បទាន ដែលអាចឱ្យសហគមន៍ទាំងមូលនោះចូលរួមយ៉ាងប្រសើរបំផុតនៅក្នុងការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែង ។

- <u>សារពើភ័ណ្ឌក្នុងវដ្តនៃការគ្រប់គ្រងព្រៃឈើ</u>

ការធ្វើសារពើភ័ណ្ឌប្រភេទនេះ គឺជាមូលដ្ឋានដ៏ចំបងក្នុងការធ្វើសេចក្តីសំរេចចិត្តលើការគ្រប់គ្រង ហើយជាឧបករណ៍ដ៏សំខាន់ និង ចាំបាច់ក្នុងការគ្រប់គ្រងដីព្រៃសម្បទានប្រកបដោយនិរន្តរភាព ។ ក្នុងមួយវដ្តនៃការគ្រប់គ្រង សារពើភ័ណ្ឌមាន ៥ ដំណាក់កាល ដែលតំរូវឱ្យផ្តល់នូវពត៌មានសំរាប់ធ្វើផែនការនៅក្នុងកិរិតផ្សេងៗ :

១- សារពើភ័ណ្ឌព្រៃឈើកិរិតស្វែងយល់

២- សារពើភ័ណ្ឌព្រៃឈើ គំរិតគ្រប់គ្រង

៣- សារពើភ័ណ្ឌព្រៃឈើមុនពេលប្រមូលផល

៤- សារពើភ័ណ្ឌព្រៃឈើក្រោយពេលប្រមូលផល (២ ឆ្នាំ ក្រោយពីធ្វើការដកហូត) សូមមើលតារាងខាងក្រោម

៥- សារពើភ័ណ្ឌព្រៃឈើក្រោយពេលប្រមូលផល (៥ ឆ្នាំ ក្រោយពីធ្វើការដកហូត)

• *សារពើភ័ណ្ឌព្រៃឈើកំរិតស្វែងយល់*

| ពេលវេលាអនុវត្ត | គោលបំណង | ភាពច្បាស់លាស់ | ការទទួលខុសត្រូវ |
|---|---|---|---|
| មុនពេលប្រកាសឱ្យដេញថ្លៃសំរាប់ការផ្ដល់ព្រៃសម្បទាន | ដើម្បីទទួលបានការប៉ាន់ស្មានបរិមាណ និង គុណភាពមាឌឈើដែលអាចដកហូតបានក្នុង ១ ហ.ត | កំរិតជំរើសទាប | នាយកដ្ឋានរុក្ខា-ប្រមាញ់ |
| ប្លង់ជំរើស និង វិធីសាស្ត្រ | ការវាស់ឈើក្នុងឡូត៍គំរូសំរាប់វាស់ដើមឈើដែលមានអង្កត់ផ្ចិតលើសំបកចាប់ពី ៤៥ ស.ម ឡើងទៅក្នុងព្រៃឈើដែលមានដង់ស៊ីតេខ្ពស់ ។ | | |

• *សារពើភ័ណ្ឌព្រៃឈើ កំរិតគ្រប់គ្រង*

| ពេលវេលាអនុវត្ត | គោលបំណង | ភាពច្បាស់លាស់ | ការទទួលខុសត្រូវ |
|---|---|---|---|
| ក្នុង ១ ឬ ២ ឆ្នាំ បន្ទាប់ពីការចុះកិច្ចសន្យាព្រៃសម្បទាន | ដើម្បីផ្ដល់ពត៌មានជាក់លាក់លើគុណភាព និង បរិមាណឈើគ្រប់គ្រាន់ដើម្បីគណនាបរិមាណដកហូតប្រចាំឆ្នាំ សំរាប់ព្រៃសម្បទានទាំងមូល និងរៀបចំផែនការគ្រប់គ្រង ១០ ឆ្នាំ | ប៉ាន់ស្មានមាឌលូកលាស់រួមសំរាប់គ្រប់ប្រភេទឈើទំហំលើសពី ១០ ស.ម ក្នុងកំរិតលំអៀង ± ១០% នៅកំរិតប្រូបាប៊ីលីតេ ៩៥% ។ | ព្រៃសម្បទានិក<br>នាយកដ្ឋានរុក្ខា-ប្រមាញ់ត្រួតពិនិត្យដោយកន្លែងដើម្បីបញ្ជាក់ការពិតលើលទ្ធផលសារពើភ័ណ្ឌរបស់ព្រៃសម្បទានិក |
| ប្លង់ជំរើស និង វិធីសាស្ត្រ | ចង្អោមគំរូព្រៃ-ពត៌មានលំអិតសូមមើលឯកសារ UNDP FAO សារពើភ័ណ្ឌព្រៃឈើសំរាប់ប្រទេសកម្ពុជា | | |

• *សារពើភ័ណ្ឌព្រៃឈើមុនពេលប្រមូលផល*

| ពេលវេលាអនុវត្ត | គោលបំណង | ភាពច្បាស់លាស់ | ការទទួលខុសត្រូវ |
|---|---|---|---|
| រយៈពេល ៦ ខែ មុនចាប់ផ្ដើមអនុវត្តការប្រមូលផល | ដើម្បីកំណត់ពីៈ<br>- អត្រាដកហូតមាឌឈើក្នុង ១ ហ.ត<br>- ការរក្សាដើមឈើបន្សល់ទុកពូជ | ការវាស់រាប់ ១០០% នៃដើមឈើទាំងអស់ត្រង់កំពស់ ១.៣ ម ពីដី អាស្រ័យតាមទំហំអង្កត់ផ្ចិតអប្បបរមាដែលអនុញ្ញាតឱ្យកាប់ ។ | ព្រៃសម្បទានិក<br>នាយកដ្ឋានរុក្ខា-ប្រមាញ់ត្រួតពិនិត្យដោយកន្លែងដើម្បីបញ្ជាក់ការពិតលើលទ្ធផលសារពើភ័ណ្ឌរបស់ព្រៃសម្បទានិក |
| ប្លង់ជំរើស និង វិធីសាស្ត្រ | សារពើភ័ណ្ឌ ១០០% (ដៅអោយកាប់ ឬ ដៅបន្សល់ទុក) លើគ្រប់ដើមឈើទាំងអស់ ដែលមានអង្កត់ផ្ចិតលើសំបកធំជាង ឬ ស្មើអង្កត់ផ្ចិតអប្បបរមាដែលអនុញ្ញាតអោយកាប់ ។ | | |

+ សារពើភ័ណ្ឌព្រៃឈើក្រោយពេលប្រមូលផល - I

| ពេលវេលាអនុវត្ត | គោលបំណង | ភាពច្បាស់លាស់ | ការទទួលខុសត្រូវ |
|---|---|---|---|
| ២ ឆ្នាំ ក្រោយពីការបញ្ចប់នូវរាល់ដំណើរការអាជីវកម្មក្នុងព្រៃគុបប្រចាំឆ្នាំ | ដើម្បីបាន់ប្រមាណពីៈ<br>១- ផលសរុបនៃមាឌឈើឈរដែលនៅសល់ និងសមាសភាគរបស់វា ។<br>២- ស្ថានភាពនៃការបន្តពូជឡើងវិញ ។<br>៣-ការខូចខាតក្នុងការកាប់រំលំ សំរាប់កំណត់នូវតំរូវការការងាររុក្ខវប្បកម្ម ដើម្បីធានាការប្រមូលផលនៅថ្ងៃអនាគត ។ | កំរិតជំរើសទាប | ព្រៃសម្បទានិក |
| ប្លង់ជំរើស និងវិធីសាស្ត្រ | ប្រឡោះព្រៃដែលមានឡូត៍គំរូទំហំ ១០ម x ១០ម សំរាប់ដើមឈើមានអង្កត់ផ្ចិតលើសំបកចាប់ពី ១០ស.ម ឡើងទៅត្រង់កំពស់ ១.៣ម ពីដី និងឡូត៍គំរូទំហំ ២ម x ២ម ដែលមានគំលាតពីគ្នា២០០ម សំរាប់ដំណុះកូនឈើ ។ | | |

+ សារពើភ័ណ្ឌព្រៃឈើក្រោយពេលប្រមូលផល - II

| ពេលវេលាអនុវត្ត | គោលបំណង | ភាពច្បាស់លាស់ | ការទទួលខុសត្រូវ |
|---|---|---|---|
| ៥ ឆ្នាំ ក្រោយពីការបញ្ចប់នូវរាល់ដំណើរការអាជីវកម្មក្នុងព្រៃគុបប្រចាំឆ្នាំ | ដើម្បីបាន់ស្មានការវិវត្តន៍នៃធនធាននៅពេលអនាគតសំរាប់ខួបអាជីវកម្មលើកក្រោយទៀត និង ការធ្វើអន្តរាគមន៍ដ៏សមរម្យ ។ | កំរិតជំរើសទាប | នាយកដ្ឋានរុក្ខា-ប្រមាញ់ |
| ប្លង់ជំរើស និង វិធីសាស្ត្រ | ប្រឡោះព្រៃដែលមានឡូត៍គំរូទំហំ ១០ម x ១០ម សំរាប់ដើមឈើមានអង្កត់ផ្ចិតលើសំបកចាប់ពី ១០ស.ម ឡើងទៅត្រង់កំពស់ ១.៣ម ពីដី និង ឡូត៍គំរូទំហំ ២ម x ២ម ដែលមានគំលាតពីគ្នា ២០០ម សំរាប់ដំណុះកូនឈើ | | |

បង្កើតពត៌មានរុក្ខវប្បកម្ម ដើម្បីធ្វើការសំរបសំរួលការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ព្រៃសម្បទានិកទាំងអស់ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានរុក្ខា-ប្រមាញ់ ដើម្បីទទួលធ្វើនូវសកម្មភាពដូចខាងក្រោមៈ

- ការពារថែរក្សា និង ជួយក្នុងការវាស់រាប់ឡូត៍គំរូអចិន្ត្រៃយ៍ ( ឡូត៍ដំណុះឈើ ) ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៨ និង សំរួលការបង្កើតឡូត៍គំរូអចិន្ត្រៃយ៍ថែមទៀត ដើម្បីបង្កើតពត៌មានអំពីកំណើនល្អតលាស់ និង ទិន្នផល
- បង្កើតតារាងមាឌ សំរាប់រាល់ប្រភេទឈើសំខាន់ៗទាំងអស់
- សារពើភ័ណ្ឌព្រៃឈើបន្តបន្ទាប់ ( CFI ) ក្នុងព្រៃសម្បទានដែលមានទំហំលើសពី ១០០.០០០ហ.ត ដើម្បីទទួលបាននូវពត៌មានបន្តបន្ទាប់
- ប្រមូលផ្តុំ និង ផ្តល់ពត៌មានអំពីមេគុណអថេរភាពសំរាប់ស្រទាប់ព្រៃសំខាន់ៗ
- រួមចំណែកលើចំណេះដឹងអំពីរុក្ខសាស្ត្រ ចាត់ថ្នាក់ពីរុក្ខជាតិ និង វដ្តចេញផ្កា-ផ្លែនៃប្រភេទឈើ
- សំរួលដល់ការស្រាវជ្រាវរុក្ខវប្បកម្ម ដើម្បីធានាការបន្តពូជឡើងវិញនៃប្រភេទឈើដែលចង់បាន នៅក្នុងព្រៃប្រមូលផលរួចហើយ ។

## ៤-៦- ការធ្វើផែនទី

រាល់ការធ្វើសារពើភ័ណ្ឌ និង សកម្មភាពនៃការធ្វើផែនការទាំងអស់អាស្រ័យលើតំលៃ និង ការប្រើប្រាស់ផែនទីដែលសមស្របទៅនឹងគោលបំណង និង តំរោងសារពើភ័ណ្ឌ ព្រមទាំងកសាងផែនការគ្រប់គ្រង ។ បច្ចេកវិជ្ជានៃប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) នឹងត្រូវបានយកមកប្រើក្នុងការបង្កើតផែនទី សំរាប់ការធ្វើផែនការ និង សំរាប់គោលបំណងប្រតិបត្តិការប្រមូលផល ។

## ៤-៧- ការគ្រប់គ្រងមូលដ្ឋានទិន្នន័យ

ការធ្វើផែនការ និង ប្រតិបត្តិការគ្រប់គ្រង នឹងប្រើប្រាស់ប្រព័ន្ធទិន្នន័យមួយ សំរាប់ធ្វើការកត់ត្រា ចាត់ថ្នាក់ វិភាគ ការធ្វើរបាយការណ៍នៃព័ត៌មានស្តីពីបញ្ហាគ្រប់គ្រងព្រៃឈើ ។ ទិន្នន័យដែលត្រូវបានគ្រប់គ្រងយ៉ាងត្រឹមត្រូវ ជាជំនួយដ៏មានថាមពល សំរាប់ការសំរេចចិត្តប្រកបដោយប្រសិទ្ធិភាពដែលនាំដល់ការបង្កើតការអនុវត្តន៍ និងត្រួតពិនិត្យកម្មវិធីគ្រប់គ្រងដែលបានលើកជាផែនការ ។

ព័ត៌មាននៃការគ្រប់គ្រងព្រៃឈើ យ៉ាងហោចណាស់គួរមានបញ្ចូលនូវទិន្នន័យដូចខាងក្រោម :

- ឋានលេខាវិទ្យា និងលក្ខណៈសណ្ឋានដីផ្សេងទៀត
- ធនធានឈើដែលបានពីការធ្វើសារពើភ័ណ្ឌ និង ការវាយតំលៃក្នុងការប្រមូលផលព្រៃឈើ
- ការលក់ឈើហ៊ុប និង ផលិតផលព្រៃឈើផ្សេងទៀត
- អំពីរុក្ខវប្បកម្ម
- ទិន្នន័យស្តីពីជីវៈចំរុះ
- ការប្រើប្រាស់ព្រៃឈើដោយសហគមន៍មូលដ្ឋាន
- ទិន្នន័យស្តីពីការការពារព្រៃឈើ ។

## ៤-៨- ការវាយតំលៃការគ្រប់គ្រង និង ការធ្វើផែនការយុទ្ធសាស្ត្រប្រមូលផលព្រៃឈើ

ការវាយតំលៃការគ្រប់គ្រង ដែលដឹកនាំដោយផ្ទាល់ចំពោះការរៀបចំបង្កើតផែនការប្រមូលផលព្រៃឈើជាយុទ្ធសាស្ត្រលើមូលដ្ឋាន អនុតំបន់ (Compartment) នឹងត្រួតពិនិត្យមើលថាតើនៅពេលណា ទីកន្លែងណា ប្រភេទនៃការប្រមូលផលព្រៃឈើយ៉ាងដូចម្តេចខ្លះ ដែលសមស្របទៅនឹងការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែង ។ ការធ្វើផែនការប្រមូលផលព្រៃឈើជាយុទ្ធសាស្ត្រ មិនគួរធ្វើឡើងដោយគ្មានការពិចារណាលើបញ្ហាដែលមានឥទ្ធិពលដល់ការគ្រប់គ្រងព្រៃឈើ ដែលមានលក្ខណៈកាន់តែទូលំទូលាយនេះឡើយ ។ វាគឺជាផ្នែកមួយនៃផែនការគ្រប់គ្រងព្រៃឈើ និង មិនគួរធ្វើជារបាយការណ៍នៃការធ្វើផែនការដាច់ដោយឡែក និង ឯករាជ្យនោះទេ ។

ការធ្វើផែនការប្រមូលផលព្រៃឈើជាយុទ្ធសាស្ត្រត្រូវផ្អែកលើការយល់ដឹងស្តីពី :

- ផ្ទៃដីព្រៃដែលបានកំណត់សំរាប់គោលបំណងផលិតកម្មឈើ ឬផលព្រៃឈើផ្សេងទៀត គឺជាផ្ទៃដីប្រមូលផលសុទ្ធសាធ ។ ផ្ទៃដីប្រមូលផលសុទ្ធសាធ មិនរួមបញ្ចូលនូវតំបន់ទាំងឡាយណា ដែលបានកំណត់ជាតំបន់ការពាររួមទាំងតំបន់ទ្រនាប់ផងដែរ
- ការដកហូតប្រចាំឆ្នាំ ឬ ប្រចាំរយៈពេលមួយ (ខួបអាជីវកម្ម)
- ប្រព័ន្ធរុក្ខវប្បកម្មដែលត្រូវអនុវត្ត
- ទំហំនៃការប្រមូលផលព្រៃឈើខុសច្បាប់ ឬការកាប់ដោយរំលោភដែលអាចកើតមានឡើង

ផែនទី នៃផែនការប្រមូលផលព្រៃឈើជាយុទ្ធសាស្ត្រ ( មាត្រដ្ឋានមិនលើសពី ១:២០ ០០០) នឹងបង្ហាញពី :

- ប្រភេទព្រៃ ឋានលេខា ហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់ និង គ្រោងបង្កើតថ្មី

- ដីព្រៃឈើដែលត្រូវទុកសំរាប់ការពារទីជំរាល ឬ ការអភិរក្សជីវៈចំរុះ ឬ សំរាប់ហេតុផលនៃការអភិវឌ្ឍន៍សហគមន៍
- ផ្ទៃដីដែលបានដាក់ស្នើដើម្បីប្រមូលផលព្រៃឈើ ត្រូវបានបែងចែកជាព្រៃគុបសំរាប់ប្រមូលផលប្រចាំឆ្នាំ ដែលអាចកំណត់ និង ទទួលស្គាល់ជាក់ស្តែងនៅលើទីវាល
- កន្លែងដែលមានបញ្ហាសំខាន់ៗកើតមានឡើងដូចជា ផ្លូវទឹកឆ្លងកាត់ ឬ វាលភក់ល្បប់ដែលត្រូវតែជំនះក្នុងពេលកសាងប្រព័ន្ធផ្លូវដឹកជញ្ជូន ឬប្រតិបត្តិការប្រមូលផលព្រៃឈើ
- ផ្ទៃដីមិនមែនព្រៃ
- ទីតាំងនៃសហគមន៍ដែលអាចត្រូវប៉ះពាល់ដោយការប្រមូលផល ឬ ប្រតិបត្តិការដឹកជញ្ជូន ។

## ៥- ការកំណត់ និង ការធ្វើនិយតកម្មទិន្នផល

និយតកម្មទិន្នផលក្នុងផលិតកម្មព្រៃឈើ គឺជាការកំណត់តាមគ្រប់ទំហំបរិមាណប្រមូលផលដែលផ្អែកតាមមូលដ្ឋានមួយធ្វើយ៉ាងណាឱ្យមានតុល្យភាពជាមួយនឹងកំណើនលូតលាស់នៃព្រៃឈើ និង ដើម្បីត្រួតពិនិត្យមាឌឈើកាប់ដកហូតដើម្បីធានាថាបរិមាណនៃការដកហូតមិនលើស ហើយក៏មិនក្រោមលទ្ធភាពផ្តល់ផលរបស់ព្រៃដែរ ។ និយតកម្មទិន្នផលនេះក៏ត្រូវពិចារណាពីបរិស្ថាន និង សហគមន៍ផងដែរ ។

### ៥-១- លក្ខណៈវិនិច្ឆ័យនៃផលិតកម្មឈើដោយនិរន្តរភាព

- ការគ្រប់គ្រងព្រៃឈើមាននិរន្តរភាព លុះត្រាតែកំណើនលូតលាស់មធ្យមប្រចាំឆ្នាំរបស់ព្រៃឈើចំរុះអាយុមានរបាយចំណាត់ថ្នាក់អង្កត់ផ្ចិតស្មើ ឬធំជាងបន្តិចបន្តួចធៀបនឹងបរិមាណឈើសរុបដែលបានធ្វើអាជីវកម្ម ក្នុងអំឡុងពេលនៃការធ្វើផែនការមិនតិចជាង ១៥ ឆ្នាំ ដោយធានាបានប្រភេទរចនាសម្ព័ន្ធ និង មុខងាររបស់ព្រៃដែលនឹងមិនត្រូវបានថយចុះឡើយ
- ការគ្រប់គ្រងព្រៃមិនមាននិរន្តរភាព ប្រសិនបើបរិមាណផលសរុបនៃការធ្វើអាជីវកម្មលើសកំណើនលូតលាស់មធ្យមប្រចាំឆ្នាំ ក្នុងអំឡុងពេលនៃការធ្វើផែនការមិនតិចជាង ១៥ ឆ្នាំ នោះ ។

### ៥-២- ការពិចារណាពីឧបសគ្គផ្នែក សង្គម-សេដ្ឋកិច្ច ក្នុងការកំណត់ទិន្នផលឈើ

ការកំណត់ទិន្នផលឈើឱ្យមាននិរន្តរភាពក្នុងព្រៃផ្តល់ផល មិនត្រឹមតែពិចារណាលើបញ្ហាបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែត្រូវពិចារណាផងដែរ ពីការលំបាកផ្នែកសង្គម និង សេដ្ឋកិច្ចក្នុងការប្រមូលផលព្រៃឈើដែលត្រូវធ្វើផែនការ ។ ស្ថានភាពបច្ចេកទេសសង្គម និង សេដ្ឋកិច្ចទូទៅ ទាក់ទងនឹងការកំនត់ទិន្នផលព្រៃឈើនៃព្រៃសម្បទានក្នុងប្រទេសកម្ពុជា ដែលអាចត្រូវបានសង្ខេបដូចតទៅ:

- ការយល់ដឹងពីឈើឈរ និង ការលូតលាស់ឡើងវិញនៃធនធានព្រៃឈើមានលក្ខណៈមិនគ្រប់គ្រាន់ ឬស្ទួចស្តើងបំផុតចំពោះប្រភេទព្រៃឈើភាគច្រើន ដែលការងាររៀបចំគ្រប់គ្រងថ្មីកំពុងត្រូវបានអនុវត្តដោយមាត្រព័ន្ធក្នុងដំណាក់កាលដំបូង
- មានចំណេះដឹងតិចតួចពីកំណើនលូតលាស់នៃព្រៃឈើ ឬ ឌីណាមិចអេកូឡូស៊ីនៃប្រភេទព្រៃនានា ដែលការប្រមូលផលព្រៃឈើកំពុងប្រតិបត្តិ ហើយគុណភាពនៃពត៌មានដែលប្រមូលបាននៅមានការមន្ទិលសង្ស័យ ឬមិនទាន់បានធ្វើការសាកល្បង នៅក្នុងព្រៃទាំងនេះនៅឡើយ
- ព្រៃឈើភាគច្រើនបាន និង កំពុងទទួលរងការខូចខាតដោយការកាប់ឈើល្មើសច្បាប់ និង ដោយការប្រមូលឈើថាមពលក្នុងពេលកន្លងមក ឬ ការប្រមូលផលបន្តបន្ទាប់ដោយព្រៃសម្បទានិក ដូច្នេះការធ្វើនិទស្សន៍ពីទិន្នផលដែលពឹងផ្អែកលើការប្រើប្រាស់វិធីសាស្ត្រកំណត់កំណើនមាឌឈើអាចធ្វើឱ្យមានការយល់ខុស

- ចំនួនបុគ្គលិក និង ធនធានហិរញ្ញវត្ថុ នាយកដ្ឋានរុក្ខា-ប្រមាញ់នៅមានកំណត់ ។ ដូចគ្នានេះដែរសមត្ថភាពខាងវិជ្ជាជីវៈព្រៃឈើរបស់ព្រៃសម្បទានិក ភាគច្រើនមានកំរិតកំណត់ និង ធ្វើនិយតកម្មទិន្នផលដោយខ្លួនឯង។ នៅដំណាក់កាលបច្ចុប្បន្ន ការអភិវឌ្ឍន៍ស្ថាប័ននាយកដ្ឋានរុក្ខា-ប្រមាញ់ និង ព្រៃសម្បទានិកប្រើប្រាស់នូវបច្ចេកវិទ្យាសមស្រប ដើម្បីកំនត់ទិន្នផល ដែលពឹងផ្អែកជាបឋមលើលក្ខណៈវិនិច្ឆ័យសាមញ្ញនៃផ្ទៃដីព្រៃ មាឌឈើឈរ និង ការកំណត់អង្កត់ផ្ចិតឈើអប្បបរមាអនុញ្ញាតអោយកាប់ ។

## ៥-៣- ការកំណត់បរិមាណឈើអនុញ្ញាតអោយកាប់ប្រចាំឆ្នាំ (AAC) ក្នុងព្រៃមិនទាន់ខូចខាត

ទាក់ទងនឹងបទពិសោធន៍ដ៏សាមញ្ញ ប៉ុន្តែជាវិធីសាស្ត្របច្ចេកទេសសមរម្យ សំរាប់កំណត់បរិមាណឈើអនុញ្ញាតឱ្យកាប់ចំពោះព្រៃសម្បទានដែលមានបំរែបំរួល មាឌឈើស្តុកស្ដែងហើយនិង ទាញយកផលដោយអ្នកផលិត ដោយប្រើប្រាស់ទិន្នន័យផ្ទៃដី និង មាឌឈើឈរ ។

## ៥-៤- ការធ្វើផែនការនិយតកម្មទិន្នផល

ការធ្វើផែនការនិយតកម្មទិន្នផលនៃបរិមាណឈើអនុញ្ញាតឱ្យកាប់ប្រចាំឆ្នាំ ក្នុងព្រៃគុបទីមួយៗ នឹង បញ្ជាក់ពីទីកន្លែង និង លក្ខខណ្ឌដែលការប្រមូលផលអាចដកហូតយកបាន។ គោលការណ៍ណែនាំពីការធ្វើផែនការនិយតកម្មទិន្នផលសំរាប់ព្រៃគុបទីមួយៗ នឹងយកមកពិចារណាលើពតិមានបច្ចេកទេសព្រៃឈើ និង បញ្ជាក់នូវផ្ទៃដីព្រៃទាំងឡាយដែលត្រូវកាត់ចេញពីការប្រមូលផលដើម្បីផលប្រយោជន៍បរិស្ថាន និងសង្គម។ ឈើចំណីផ្លូវនឹងត្រូវបញ្ចូលជាផ្នែកមួយនៃបរិមាណឈើអនុញ្ញាតឱ្យកាប់ប្រចាំឆ្នាំ តែមិនមែនជាទិន្នផលបន្ថែមឡើយ។

## ៦- ការពិចារណាពីសេដ្ឋកិច្ច

បញ្ហាសេដ្ឋកិច្ច ដែលមានឥទ្ធិពលលើការគ្រប់គ្រងព្រៃសម្បទាន នឹងត្រូវយកមកពិចារណាក្នុងអំឡុងពេលនៃការធ្វើផែនការគ្រប់គ្រងដូចខាងក្រោម :

- ព្រៃតំបន់ត្រូពិចអាចនៅគង់វង្ស និង ត្រូវបានយកមកគ្រប់គ្រងជាធនធានធម្មជាតិអចិន្ត្រៃយ៍ ប្រសិនបើដីព្រៃត្រូវបានគេគិតថាមានតំលៃនៅពេលដែលគំរបព្រៃត្រូវបានរក្សាទុក ប្រសើរជាងដីព្រៃត្រូវបានកាប់សំអាត និង ប្រែក្លាយ ឱ្យទៅជាការប្រើប្រាស់ដីផ្សេងទៀត នៅក្នុងរយៈពេលនៃខួបធ្វើអាជីវកម្ម
- ទីតាំងព្រៃ ឋានលេខា ភាពអាចចូលដល់ព្រៃ ប្រភេទដី និង ព្រៃ អាកាសធាតុ និង មាឌឈើដែលអាចធ្វើការដកហូតបាន
- ថ្លៃឈើឈរ ថ្លៃផលិតផលឈើកែច្នៃ អត្រាការប្រាក់នៃថវិកាដែលបានខ្ចី រយៈពេលខួបអាជីវកម្ម និង ថ្លៃដើមសំរាប់ប្រតិបត្តិការសមរម្យ
- តំលៃបរិស្ថាននៃទីជំរាលដែលរាប់បញ្ចូលទាំងចរន្តទឹកហូរក្នុងស្ទឹង សារៈសំខាន់នៃជីវៈចំរុះ ទេសភាព និង ការអភិរក្សសត្វព្រៃ
- ភាពពឹងពាក់អាស្រ័យជាប្រពៃណីនៃសហគមន៍ និង តំលៃសង្គមផ្សេងទៀតនៃព្រៃឈើ សំរាប់ជាអាហារ រុក្ខជាតិឱសថ និង ផលិតផលផ្សេងទៀត។

## ៧- ការយល់ព្រមលើផែនការគ្រប់គ្រងព្រៃឈើ

ផែនការគ្រប់គ្រងព្រៃសម្បទានរយៈពេលវែង នឹងត្រូវបានឯកភាពដោយរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើអនុសាសន៍ ផ្ដល់ដោយនាយកដ្ឋានរុក្ខា-ប្រមាញ់ ។

ផែនការប្លុកត្រូវបានរៀបចំដើម្បីផ្តល់ការពណ៌នាលំអិតពីប្រតិបត្តិការប្រមូលផលព្រៃឈើនៅក្នុងព្រៃគុបប្រចាំឆ្នាំ ។ ទំរង់ និងមាតិកានៃផែនការប្លុកត្រូវបានបញ្ជាក់ក្នុង *ក្រមបច្ចេកទេស ការធ្វើផែនការគ្រប់គ្រងព្រៃឈើ និងក្រមបច្ចេកទេសអនុវត្ត ការប្រមូលផលព្រៃឈើ* ។ ផែនការប្លុក ផ្តល់នូវគោលបំណងជាមូលដ្ឋាន សំរាប់ការតាមដានត្រួតពិនិត្យ ការអនុវត្តន៍ប្រមូលផល ព្រៃឈើនៅនឹងកន្លែង ដើម្បីធានានូវការអនុវត្តន៍តាមក្រម និងគោលបំណងនៃការធ្វើផែនការទូទៅ ។

១០- <u>ការតាមដាន និង ការធ្វើរបាយការណ៍</u>

ការសំរេចបានការតាមដាន អាស្រ័យលើការអនុវត្តន៍បញ្ញត្តិទាំងឡាយ ដែលបានកំណត់នៅក្នុងផែនការប្រមូលផល ប្រចាំឆ្នាំ ផែនការប្លុក និង *ក្រមបច្ចេកទេសអនុវត្តការប្រមូលផលព្រៃឈើ*។ ការធ្វើកំណត់ហេតុ និង ការធ្វើរបាយការណ៍ទាំងនេះ ទៅនាយកដ្ឋានរុក្ខា-ប្រមាញ់ និងត្រូវបានអនុវត្តជាមូលដ្ឋាន សំរាប់ដំណើរការការងារគ្រប់គ្រងឱ្យមានគម្លាភាព។ ទាំងនេះមាន សារៈប្រយោជន៍ដូចតទៅ:

- ដើម្បីរក្សាបាននូវការត្រួតពិនិត្យលើការអនុវត្តន៍ការប្រមូលផលព្រៃឈើ
- ដើម្បីតាមដានលើការប្រមូលផលព្រៃឈើដែលមិនបានទទួលការអនុញ្ញាត និង សកម្មភាពល្មើសច្បាប់ផ្សេងទៀត
- ដើម្បីវាយតំលៃកម្មវិធីគ្រប់គ្រងព្រៃឈើ
- ដើម្បីវាយតំលៃលើលទ្ធផលនៃការគ្រប់គ្រង និង ការចាត់ចែងរបស់ព្រៃសម្បទានិក
- ដើម្បីធ្វើការកែតម្រូវចំពោះផែនការប្រមូលផលប្រចាំឆ្នាំ ស្របទៅតាមការសំរេចបាន និង ការលំបាកក្នុង ការអនុវត្តន៍ផែនការ
- ដើម្បីផ្តល់ពត៌មានសំរាប់ពិនិត្យផែនការគ្រប់គ្រងឡើងវិញ
- ដើម្បីតាមដានតំបន់ព្រៃឈើរយៈពេលវែង ។

ទោះជាតំរូវការតាមដានជាក់ស្តែងនៃព្រៃសម្បទាននីមួយៗមានលក្ខណៈច្បាស់លាស់ក៏ដោយ ក៏នៅមានគន្លឹះមួយចំនួន ដែលគួរត្រូវបានប្រើប្រាស់ជារង្វាស់វាយតំលៃការប្រតិបត្តិដែរ ។ ការសង្ខេបអំពីជំរើសគន្លឹះដែលត្រូវបានប្រើប្រាស់ជារង្វាស់វាយ តំលៃសំរាប់ការប្រតិបត្តិការងារតាមដានត្រូវបានសង្ខេបក្នុង *ក្រមបច្ចេកទេស ការធ្វើផែនការគ្រប់គ្រងព្រៃឈើ និង ក្រមបច្ចេក ទេសអនុវត្តប្រមូលផលព្រៃឈើ* ។